00404856

ឯកសារ/Nº: A296/2

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

# ការិយាល័យសហចៅក្រមស៊ើបអង្កេត

ភ្នំពេញ ថ្ងៃទី ៦ ខែតុលា ឆ្នាំ២០០៩

ឯកសារទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/date de reception): 25 / 11 / 2009
ម៉ោង (Time/Heure) : 10:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: C.A. Fey

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date /Date de certification): 25 / 11 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: C.A. Fey

**ឯកឧត្តម សាត ឈន់**

ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**នៃរាជរដ្ឋាភិបាលកម្ពុជា**

រាជធានីភ្នំពេញ

ឯកឧត្តមជាទីគោរព

កាលពីថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០០៩ ខ្ញុំ បានឲ្យក្រឡាបញ្ជីប្រគល់ជូនឯកឧត្តមនូវដីកាកោះមួយដើម្បីស្តាប់ចម្លើយឯកឧត្តមក្នុងនាមជាសាក្សី នៅថ្ងៃទី ៦ ខែតុលា ឆ្នាំ២០០៩ ដោយបានបញ្ជាក់ថា កាលបរិច្ឆេទនោះ គ្រាន់តែជាកាលបរិច្ឆេទបឋមតែប៉ុណ្ណោះ និង ថា ក្រឡាបញ្ជីរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត នឹងធ្វើទំនាក់ទំនងជាមួយលេខាធិការដ្ឋានរបស់ឯកឧត្តមដើម្បីធានាថាកាលបរិច្ឆេទនោះ សមស្របជាមួយនឹងធុរៈរបស់ឯកឧត្តម ឬ ត្រូវកំណត់យកកាលបរិច្ឆេទថ្មីមួយទៀត។

ទោះបីជាមានការខំប្រឹងប្រែងជាច្រើនដងនៅក្នុងការទាក់ទងទៅបុគ្គលទាំងឡាយដែលធ្វើការជាប់ជាមួយឯកឧត្តមក៏ដោយ ក៏ក្រឡាបញ្ជីមិនបានទទួលចម្លើយតបណាមួយពីខុទ្ទកាល័យរបស់ឯកឧត្តមដែរ ហើយការស្តាប់ចម្លើយរបស់ឯកឧត្តម ក៏មិនបានធ្វើដែរ។



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១
ទូរស័ព្ទលេខ +៨៥៥(0)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(0)២៣ ២១៨៩៤១។

ឈមនឹងស្ថានភាពបែបនេះ ខ្ញុំ បានបញ្ជាដល់ក្រឡាបញ្ជី ទី១ ឱ្យធ្វើរបាយការណ៍ជាលាយលក្ខណ៍អក្សរមកខ្ញុំអំពីកិច្ចការដែលគាត់បានធ្វើកន្លងមក និង ទី២ ស្នើសុំណាត់ជួបជាមួយឯកឧត្តម **ជូ វិចិត្រ** នាយខុទ្ទកាល័យរបស់ឯកឧត្តម។

ខ្ញុំ គិតថាប្រហែលជាយើងមានការយល់ច្រឡំលើគ្នាតែប៉ុណ្ណោះ ពីព្រោះថា ជាអាទិ៍ ឯកឧត្តម ធ្លាប់បានធ្វើការប្រកាសជាសាធារណៈកាលពីថ្ងៃទី ១៣ ខែធ្នូ ឆ្នាំ២០០៦ ថា ឯកឧត្តម ត្រៀមខ្លួនរួចហើយដើម្បីផ្តល់សក្ខីកម្មនៅក្នុងនីតិវិធីដែលកំពុងដំណើរការ ប្រសិនបើតុលាការខ្មែរក្រហម ធ្វើការកោះហៅឯកឧត្តម។ ទង្វើនេះ ជាអ្វីដែលគ្រប់ៗគ្នាគិតថាជាការសមហេតុសមផលៈ វាដូចជាមិនសមទេ ដែលសមាជិកម្នាក់នៃរដ្ឋាភិបាលដែលបានផ្តួចផ្តើមគំនិតបង្កើតតុលាការនេះ បែរជាមិនសហការជាមួយតុលាការនេះ និង មិនជួយសម្រួលដល់ដំណើរការរបស់វា។

ខ្ញុំ សង្ឃឹមថាការស្តាប់ចម្លើយនេះ នឹងអាចត្រូវរៀបចំឡើងក្នុងពេលវេលាសមរម្យមួយហើយ ក្នុងពេលរង់ចាំនេះ សូម ឯកឧត្តម ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់បំផុតអំពីខ្ញុំ។

**សហចៅក្រមស៊ើបអង្កេត**

Marcel Lemonde